

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :២៣៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាឥន្ទ្រាជីវៈមេធាវី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២៦/០១៩ ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សម្រេច

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាវិជ្ជាជីវៈមេធាវី ដែលសរសេរជាអក្សរកាត់ថា **ស.វ.ម**.។

មាត្រា២ .-

ស.វ.ម. មានមុខងារ និងការកិច្ច ដូចតទៅ៖

- រៀបចំការប្រឡងប្រជែងជ្រើសរើសឱ្យចូលរៀនវិជ្ជាជីវៈមេធាវីនៅ **ស.វ.ម**. ការប្រឡងយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងដល់សិស្សមេធាវី
- រៀបចំការបណ្តុះបណ្តាលបន្តតាមរយៈវគ្គសុក្រឹតការនិងវគ្គវិក្រឹតការដល់មេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងការបណ្តុះបណ្តាលផ្សេងទៀតតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី
- រៀបចំផែនការបណ្តុះបណ្តាល និងកម្មវិធីសិក្សា ព្រមទាំងការជ្រើសរើសគ្រូបណ្តុះបណ្តាលជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច
- រៀបចំផែនការយុទ្ធសាស្ត្រដើម្បីអភិវឌ្ឍគុណភាពនៃការបណ្តុះបណ្តាល
- រៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់ការបណ្តុះបណ្តាលនៅ **ស.វ.ម**. ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច
- រៀបចំវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី វិញ្ញាបនបត្រសុក្រឹតការវិជ្ជាជីវៈមេធាវី វិញ្ញាបនបត្រវិក្រឹតការវិជ្ជាជីវៈមេធាវី និងវិញ្ញាបនបត្របញ្ជាក់ការសិក្សាផ្សេងទៀត ក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាលនៅ **ស.វ.ម**.
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការសិក្សា និងការគោរពវិន័យរបស់សិស្សមេធាវី មេធាវី និងបុគ្គលផ្សេងទៀត ដែលទទួលការបណ្តុះបណ្តាលនៅ **ស.វ.ម**.
- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ **ស.វ.ម**.
- ធ្វើរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស និងប្រចាំឆ្នាំ ជូនក្រុមប្រឹក្សាគណៈមេធាវី
- បំពេញមុខងារ និងភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាគណៈមេធាវីប្រគល់ឱ្យ។

ជំពូកទី២
ការដឹកនាំ និងការគ្រប់គ្រង

មាត្រា៣ .-

ស.វ.ម. ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាគណៈមេធាវី។

ស.វ.ម. ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវផ្នែករដ្ឋបាលដោយបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា រួមមាន ការគាំពារលើអគារ បន្ទប់សិក្សា សម្ភារបរិក្ខារសិក្សា សន្តិសុខ និងសណ្តាប់ធ្នាប់ នៅក្នុងបរិវេណនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

មាត្រា៤ .-

ស.វ.ម. ត្រូវគ្រប់គ្រងដោយនាយក ១(មួយ)រូប ដែលត្រូវជ្រើសតាំង និងបញ្ចប់មុខតំណែងដោយក្រុមប្រឹក្សាគណៈមេធាវី។

មាត្រា៥ .-

ស.វ.ម. មានលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីគាំទ្រកិច្ចដំណើរការរបស់ខ្លួន។

លេខាធិការដ្ឋាននៃ **ស.វ.ម**. ដឹកនាំដោយប្រធាន ១(មួយ)រូប ដែលត្រូវតែងតាំង និងបញ្ចប់មុខតំណែងដោយសេចក្តីសម្រេចរបស់ប្រធានគណៈមេធាវី តាមសំណើរបស់នាយក **ស.វ.ម**.។

ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននៃ **ស.វ.ម**. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

មាត្រា៦ .-

ស.វ.ម. មានរូបសញ្ញា និងត្រាដោយឡែក សម្រាប់ប្រើជាផ្លូវការក្នុងដំណើរការការងាររបស់ខ្លួន។ រូបសញ្ញា និងត្រានៃ **ស.វ.ម**. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី និងដោយត្រូវអនុវត្តស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ជំពូកទី៣
ការប្រឡងប្រជែងជ្រើសរើសសិស្សមេធាវី និងការបណ្តុះបណ្តាល

មាត្រា៧ .-

ការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងប្រជែងជ្រើសរើសសិស្សមេធាវី ដោយរួមទាំងការកំណត់ចំនួនសិស្សមេធាវីផង ព្រមទាំងការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូង និងការបណ្តុះបណ្តាលផ្សេងទៀត ត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

មាត្រា៨ .-

ជនដែលត្រូវបានអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងឱ្យចូលរៀនវិជ្ជាជីវៈមេធាវីនៅ **ស.វ.ម**. បានត្រូវបំពេញគ្រប់លក្ខខ័ណ្ឌទាំងឡាយដូចខាងក្រោម៖

១-ត្រូវមានសញ្ជាតិខ្មែរ។

២-ត្រូវមានបរិញ្ញាបត្រនីតិសាស្ត្រ ឬសញ្ញាបត្រនីតិសាស្ត្រដែលមានតម្លៃសមមូល។

៣-មិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬត្រូវបានរងទណ្ឌកម្មខាងវិន័យ ឬបទរដ្ឋបាលដូចជា ការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការដកហូតងារអំពីអំពើផ្ទុយនឹងកិត្តិយស ឬអំពើមិនស្អាតស្អំ ឬមិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ។

៤-ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។

បញ្ជីឈ្មោះបេក្ខជនដែលត្រូវបានអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងឱ្យចូលរៀនវិជ្ជាជីវៈមេធាវីនៅ **ស.វ.ម**. ត្រូវសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី។

មាត្រា៩ .-

គណៈមេប្រយោគសម្រាប់ការប្រឡងប្រជែងជ្រើសរើសសិស្សមេធាវី និងការប្រឡងយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី មានសមាសភាពចំនួន ៩(ប្រាំបួន)រូប ដូចខាងក្រោម៖

- ប្រធានគណៈមេធាវី		ប្រធាន
- តំណាងក្រសួងយុត្តិធម៌	១រូប	អនុប្រធាន
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី	១រូប	សមាជិក
- តំណាងបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា	១រូប	សមាជិក

- សមាជិកក្រុមប្រឹក្សាគណៈមេធាវី ៤រូប សមាជិក
- នាយក **ស.ទ.ម**. សមាជិក។

គណៈមេប្រយោគមានមុខងារ និងភារកិច្ច ក្នុងការគ្រប់គ្រងដំណើរការប្រព្រឹត្តទៅនៃការប្រឡងប្រជែងជ្រើសរើសសិស្សមេធាវី និងការប្រឡងយកវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី ដោយអនុវត្តស្របតាមការកំណត់របស់ក្រុមប្រឹក្សាគណៈមេធាវី ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ជាអាទិ៍ ការសម្រេចអំពីបទបញ្ជាផ្ទៃក្នុងនៃការប្រឡង ការតែងតាំងគណៈកម្មការនានានៃការប្រឡង ការត្រួតពិនិត្យដំណើរការនៃការប្រឡង ការសម្រេចអំពីបាតុភាពផ្សេងៗដែលកើតមាននៅពេលប្រឡង និងការប្រកាសលទ្ធផលនៃការប្រឡង។

មាត្រា១០ .-

សិស្សមេធាវីត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូងឱ្យបានពេញលេញតាមកម្មវិធីសិក្សា ដែលត្រូវកំណត់ដោយក្រុមប្រឹក្សាគណៈមេធាវី។

សិស្សមេធាវីដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដំបូង និងបានប្រឡងជាប់ជាស្ថាពរ ត្រូវទទួលបានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈដែលចេញដោយ **ស.ទ.ម**. និងមានការទទួលស្គាល់ពីគណៈមេធាវី។

ជំពូកទី៤
ប្រភពធនធាន

មាត្រា១១ .-

ស.ទ.ម. មានថវិកាសម្រាប់គាំទ្រដំណើរការរបស់ខ្លួន ដែលមានប្រភពពីថវិការដ្ឋ និងពីប្រភពស្របច្បាប់ផ្សេងទៀតស្របតាមអនុក្រឹត្យនេះ និងលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ថវិកាពីប្រភពរដ្ឋ គឺជាកញ្ចប់ថវិកានៅក្នុងក្របខ័ណ្ឌនៃថវិកាកម្មវិធីរបស់បណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

ស.ទ.ម. មានសិទ្ធិទទួល គ្រប់គ្រង និងចាត់ចែងធនធាន និងថវិកាដែលបានមកពីប្រភពផ្សេងទៀតដូចខាងក្រោម៖

- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណូលពីការចុះឈ្មោះរបស់បេក្ខជនប្រឡងចូលរៀនវិជ្ជាជីវៈមេធាវី
- ចំណូលពីការបង់ថ្លៃសិក្សាសម្រាប់ការចូលរៀនរបស់សិស្សមេធាវី ឬការបណ្តុះបណ្តាលមេធាវី និងជំនួយការមេធាវី ឬការបណ្តុះបណ្តាលផ្សេងទៀត
- អំណោយរបស់រដ្ឋ អំណោយឬអច្ចិយទានរបស់ឯកជន សមាគម អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ឬធនធានពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ
- ចំណូលពីប្រភពស្របច្បាប់ផ្សេងទៀត។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងធនធាន និងថវិការបស់ **ស.ទ.ម**. ត្រូវអនុវត្តស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

ជំពូកទី៥
អន្តរប្បញ្ញត្តិ

មាត្រា១២ .-

សេចក្តីសម្រេចរបស់គណៈមេធាវី និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានសេចក្តីសម្រេច ឬលិខិតបទដ្ឋានថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ជំពូកទី៦
អវសានប្បញ្ញត្តិ

មាត្រា១៣ .-

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១៣០ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ត្រូវប្តូរឈ្មោះទៅជា **សាលាវិជ្ជាជីវៈមេធាវី**។

អនុក្រឹត្យលេខ១៣០ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយអនុក្រឹត្យនេះ។

មាត្រា១៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣ រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ២០២៦

តាមយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមមហាត្តលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កើត រិទ្ធ

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ជូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ